ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ.....១០៥/២២.......

ថ្ងៃ ច័ន្ទ ១៣កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០២២

## សេចក្តីជូនដំណឹង

### អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ឈ្នះជ័យលាភីឈ្មួញជើងសារមូលបត្រឆ្នើមសម្រាប់ត្រីមាសទី២ ឆ្នាំ២០២២

ផ្សារមូលបត្រកម្ពុជា **(ផមក)** មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ជ័យលាភីឈ្មួញជើងសារមូលបត្រឆ្នើម សម្រាប់ត្រីមាសទី២ ឆ្នាំ២០២២ គឺ **ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី**។ ចាប់តាំងពីកម្មវិធីនេះ ត្រូវបានបង្កើតឡើង **ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី** បានជាប់ជ័យលាភីច្រើនជាងគេបង្អស់ក្នុងចំណោមឈ្មួញជើងសារមូលបត្រទាំង ១២ ដែលជាសមាជិករបស់ **ផមក** ដែលការវាយតម្លៃនេះគឺ ផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៣ គឺ ទំហំជួញដូរមូលបត្រសរុបរបស់អតិថិជន ចំនួនគណនីជួញដូរដែលបានបើកថ្មី និងការប្រើប្រាស់ប្រព័ន្ធជួញដូរចល័ត (MTS)របស់អតិថិជន។

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២២ នេះ ទំហំជួញដូរមូលបត្រសរុបរបស់អតិថិជនក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី មានចំនួន ៦១៥ ប៊ីលានរៀល ពោលគឺស្មើនឹង ៩៦,៩៣% នៃទំហំជួញដូរមូលបត្រសរុប ប៉ុន្តែប្រមាណ ៨៤,៦៧% នៃចំនួនគណនីជួញដូរទាំងអស់ ដែលបានបើកថ្មីជាចំណែករបស់ក្រុមហ៊ុននេះ។ ទំហំជួញដូរសរុបរបស់អតិថិជនក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី តាមរយៈប្រព័ន្ធ MTS មានចំនួន ២៤៣ ប៊ីលានរៀល ខណៈដែលចំនួនគណនីជួញដូរតាមប្រព័ន្ធ MTS ដែលបានបើកថ្មីមានចំណែក ប្រមាណ ៨៤,១៦% នៃគណនីបើកថ្មីសរុប។

គួររំលឹកផងដែរថា កម្មវិធីឈ្មួញជើងសារមូលបត្រឆ្នើមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកនូវក្រុមហ៊ុនឈ្មួញជើងសារមូលបត្រឆ្នើមប្រចាំត្រីមាសនីមួយៗ ដែលមានភាពឈានមុខគេ ក្នុងការផ្តល់សេវាកម្មឈ្មួញជើងសារមូលបត្រសម្រាប់អតិថិជនរបស់ខ្លួន។

ផ្សារមូលបត្រកម្ពុជា

CSX

Cambodia Securities Exchange

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷

លោកស្រី ហួត ចរិយា មន្ត្រីគ្រប់គ្រង

នាយកដ្ឋានប្រតិបត្តិការទីផ្សារ

អ៊ីម៉ែល÷ chakriya.hout@csx.com.kh